ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ...

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកថ្មគោល នៃខេត្តបាត់ដំបង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញបានសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ ២៤៨/១៤ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការប្រកាសបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាអាណត្តិទី២
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

ត្រូវបានទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកថ្មគោល នៃខេត្តបាត់ដំបង ក្នុងអាណត្តិទី២ ដូចមានរាយនាមខាងក្រោម:

| ល.រ | គោត្តនាម និងនាមខ្លួន | ថ្ងៃខែឆ្នាំកំណើត | មុខតំណែង |
|---|---|---|---|
| ១- | លោក **អ៊ុច អ៊ាង** | ២៤-០៧-១៩៥០ | ជាប្រធានក្រុមប្រឹក្សាស្រុក |
| ២- | លោក **អ៊ាង សារ៉ុម** | ០១-០២-១៩៥៤ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ៣- | លោកស្រី **សុ សាមឿន** | ១៤-០១-១៩៥៣ | ជាសមាជិកក្រុមប្រឹក្សាស្រុក |

| | | | |
|---|---|---|---|
| ៤- | លោក **ម៉ក់ សុខុន** | ០១-០១-១៩៥០ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ៥- | លោក **ឈួន ឧុទ្ធី** | ០១-០១-១៩៥០ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ៦- | លោក **ឃឹន សុខា** | ០១-០១-១៩៥២ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ៧- | លោកស្រី **មួន សារ៉ែន** | ០៥-១០-១៩៥២ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ៨- | លោក **អ៊ុយ អង់** | ០៦-០២-១៩៥៣ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ៩- | លោក **ផៃ ឧុឌ្ឍី** | ១៨-១០-១៩៥៤ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ១០- | លោកស្រី **តុំ តឿត** | ០៦-១២-១៩៨២ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ១១- | លោក **ហែម ចំរើន** | ០២-០៣-១៩៥០ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ១២- | លោក **សាត់ សុខខុំ** | ០៩-០៦-១៩៥៤ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ១៣- | លោក **ថា ថៃ** | ២១-០៣-១៩៥១ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ១៤- | លោក **សាន់ ឈង** | ១៥-០៣-១៩៥៦ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ១៥- | លោក **ធឿន ហេង** | ២១-០១-១៩៥៣ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ១៦- | លោក **ម៉ុត រ៉ាន់** | ០៨-០២-១៩៦០ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ១៧- | លោកស្រី **សុខ សុភាព** | ០២-០៦-១៩៧០ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ១៨- | លោក **ម៉ន ចេក** | ១៥-០១-១៩៥៩ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ១៩- | លោក **កៅ ផល្គុណ** | ០៥-០២-១៩៥៩ | ជាសមាជិកក្រុមប្រឹក្សាស្រុក។ |

**មាត្រា ២.-**

ក្នុងករណីមានសមាជិកក្រុមប្រឹក្សាណាម្នាក់បាត់បង់សមាជិកភាពពីក្រុមប្រឹក្សា ត្រូវអនុវត្តតាមបទប្បញ្ញត្តិ នៃមាត្រា ២២ និងមាត្រា ២៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា ៣.-**

ក្នុងការអនុវត្តការងារ ប្រធាន និងសមាជិកក្រុមប្រឹក្សាស្រុកថ្មគោល នៃខេត្តបាត់ដំបង ត្រូវអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋាននានាជាធរមាន។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ